# ផែនការគេចចេញពីភ្លើងឆេះផ្ទះ

Fact Sheet 12 – Community Risk Management. Revised 28/09/2004 - Khmer

- **NSW FIRE BRIGADES**
- **ACT FIRE BRIGADE**
- **NSW RURAL FIRE SERVICE**
- **ACT RURAL FIRE SERVICE**

## ហេតុការណ៍

មរណភាពនៅក្នុងផ្ទះដែលបានកើតឡើងនៅរដ្ឋ NSW នៅក្នុងគ្រោះថ្នាក់ចំនួន ២១ ដែលត្រូវបានគេស៊ើបអង្កេតតាំងពីដើមឆ្នាំ ២០០១, ក្រុមស្រាវជ្រាវ និងស៊ើបអង្កេតខាងភ្លើងឆេះនៃកងរំលត់ភ្លើងរដ្ឋ NSW បានបញ្ចេញឲ្យដឹងថា ជនរងគ្រោះចំនួន១៣នាក់ក្នុងចំណោមជនរងគ្រោះទាំងនោះប្រហែលជាអាចមានជីវិតរស់បានយ៉ាងច្រើន ប្រសិនបើគេមានផែនការជម្លៀសមួយ ដើម្បីជួយគេចេញយ៉ាងលឿនពីផ្ទះរបស់គេ។

*(ស្ថិតិត្រឹមត្រូវនាថ្ងៃទី ១៩/០៨/០២)*

## បញ្ជីឆែកមើលនៃផែនការគេចចេញពីភ្លើងឆេះផ្ទះ

ផ្ទះហើយនិងកន្លែងការងារនិមួយៗត្រូវតែមានផែនការគេចចេញពីភ្លើងឆេះមួយ។ ភ្លើងឆេះផ្ទះដោយគ្រោះថ្នាក់តាមធម្មជាតិនោះមិនអាចឲ្យប្រជាជនដឹងជាមុនឡើយ ។ ដោយគ្មានផែនការគេចចេញពីភ្លើងឆេះ លោកអ្នកដាក់ជីវិតលោកអ្នកនិងគ្រួសារលោកអ្នកនៅក្នុងគ្រោះថ្នាក់ ។ ចំពោះការធ្វើឲ្យផ្ទះលោកអ្នកមានសុវត្ថិភាពថែមទៀត សូមហាត់ជារឿយៗតាមចំណុចសំខាន់ៗនៃការគេចចេញដូចតទៅនេះ ៖

- ☐ ការដឹងផ្លូវសុវត្ថិភាពពីរចេញពីបន្ទប់និមួយៗ ។
- ☐ សូមគូរផែនការគេចចេញរបស់លោកអ្នកនៅលើក្រដាស់ហើយនិងពិគ្រោះផែនការនេះជាមួយគ្រួសារលោកអ្នក ។
- ☐ ពេលលោកអ្នកគេចចេញ សូមធ្វើឲ្យប្រាកដថាលោកអ្នកបិទទ្វារខាងក្នុងដែលនៅក្រោយលោកអ្នក ។
- ☐ សូមសំរេចយកកន្លែងជួបជុំគ្នាមួយនៅខាងក្រៅដែលមានសុវត្ថិភាព ដូចជា នៅជិតប្រអប់សំបុត្រជាដើម ។
- ☐ សូមធ្វើឲ្យប្រាកដថាបង្អួចនិងទ្វារទាំងអស់របស់លោកអ្នកអាចបើកដោយរហ័ស ប្រសិនបើ និង នៅពេលត្រូវការបើកវា ។
- ☐ សូមដាក់គ្រឿងឲ្យសញ្ញាពេលមានផ្សែង (smoke alarms) : ធ្វើតេស្តវាជារឿយៗ និងដូរថ្មយ៉ាងហោចណាស់មួយឆ្នាំម្តង ។
- ☐ (smoke alarms) អាចប្រាប់ឲ្យលោកអ្នកដឹងជាមុននូវភ្លើងឆេះ, ដូច្នេះផែនការគេចចេញក៏ជួយលោកអ្នកគេចផុតពីការស្លាប់ផងដែរ ។
- ☐ សូមហាត់តាមផែនការគេចចេញជារឿយៗជាមួយសមាជិកគ្រួសាររបស់លោកអ្នក/ អ្នកនៅក្នុងផ្ទះទាំងអស់ ។
- ☐ ប្រសិនបើមានភ្លើងឆេះនៅក្នុងផ្ទះរបស់លោកអ្នក, សូមកុំរងចាំ, *រាល់វិនាទីគឺសំខាន់ណាស់*, គេចចេញភ្លាម រួចហើយទូរស័ព្ទលេខ 000 ពីផ្ទះអ្នកជិតខាង ។
- ☐ ពេលគេចចេញហើយ, សូមនៅខាងក្រៅ, សូមកុំត្រឡប់ទៅក្នុងអាគារដែលកំពុងឆេះនោះឲ្យសោះ ។
- ☐ សូមកុំភ្លេចគិតដល់សេចក្តីត្រូវការពិសេសរបស់កូនៗ, មនុស្សចាស់ ឬអ្នកពិការផង នៅពេលគ្រោងផែនការគេចចេញរបស់លោកអ្នក ។

**ចំពោះពត៌មានថែមទៀត សូមទាក់ទងស្ថានីយ៍រំលត់ភ្លើង ឬមជ្ឈមណ្ឌលត្រួតត្រាភ្លើងតាមតំបន់លោកអ្នក ។**

**ឬ មើលវែបសៃ: www.fire.nsw.gov.au www.rfs.nsw.gov.au or www.esa.act.gov.au**

## ចំណុចសំខាន់ៗនៃសុវត្ថិភាពភ្លើងឆេះ

- សូមចងចាំថាផ្សែងពីភ្លើងឆេះនឹងធ្វើឲ្យលោកអ្នកច្របូកច្របល់ហើយលោកអ្នកពុំអាចមើលឃើញនៅក្នុងផ្សែងទេ ។
- នៅពេលទទួលទានដំណេក, លោកអ្នកនឹងពុំធុំក្លិនផ្សែងទេ ហើយតាមការពិតវានឹងធ្វើឲ្យលោកអ្នកដេកលក់ស៊ុបថែមទៀតផង ។
- គ្រឿងដុតកំដៅដោយប្រេង, ឧស្ម័ន ឬឧស ប្រហែលជាត្រូវការការថែទាំប្រចាំឆ្នាំ ។
- សូមប្រើ (fuse) តាមកំរិតដែលគេឲ្យឱវាទហើយសូមដាក់កុងតាក់អគ្គិសនីសំរាប់សុវត្ថិភាពមួយ (electrical safety switch) ។
- សុវត្ថិភាពនៃភ្លើងឆេះផ្ទះជាការសំខាន់ណាស់ចំពោះគ្រួសារទាំងអស់ ហើយការត្រៀមលក្ខណៈទុកជាមុនអាចការពារពីសោកនាដកម្មបាន ។

**ក្នុងពេលអាសន្ន សូមទូរស័ព្ទលេខ 000**